ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

គោលការណ៍ណែនាំស្តីពីការរកចំណូល របស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

គម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ADB Loan No.3166/3167-CAM & AFD Loan No.8305-CAM

ខែតុលា ឆ្នាំ ២០១៩

បញ្ជីអក្សរកាត់

ភាសាខ្មែរ	ភាសាអង់គ្លេស
ការអភិវឌ្ឍលើការគ្រប់គ្រង និងការបណ្តុះបណ្តាលប្រកបដោយភាពច្នៃប្រឌិត	Innovative Training and Management Development (ITMD)
សកម្មភាពរកចំណូល	Income Generation Activities (IGAs)
អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(អ.ប.វ)	Technical Vocational Education and Training (TVET)
គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (គ្រឹះស្ថាន អ.ប.វ)	Technical Training Institutions (TTIs)
គម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ	Technical Vocational Education and Training Sector Development Project (TVETSDP)
សៀវភៅណែនាំអំពីការអនុវត្តគម្រោង	Project Administration Manual (PAM)
វិញ្ញាបនបត្រវិជ្ជាជីវៈ	Vocational Certificate (VC)
សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១, ២, ៣	TVET Certificate 1, 2, 3 (C1, C2, C3)
ខេត្តដែលមានជនជាតិដើមភាគតិច	Indigenous Province (IP)

មុខកថា

វិស័យការងារ និងអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងកម្មវិធីនយោបាយ ក៏ដូចជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ផ្តើមចេញពីនេះ ការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ គឺជាការងារអាទិភាពក្នុងការអនុវត្តយុទ្ធសាស្ត្រទី២នៃផែនការយុទ្ធសាស្ត្ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យវិស័យនេះអភិវឌ្ឍបាននូវធនធានមនុស្សប្រកបដោយសមត្ថភាព ជំនាញ និងគុណភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ក្នុងរយៈពេលខ្លី និងវែង។

គម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVETSDP/ADB Loan No.3166/3167-CAM & AFD Loan No.8305-CAM) បានបង្កើតឱ្យមានយុទ្ធសាស្ត្រការអភិវឌ្ឍលើការគ្រប់គ្រង និងការបណ្តុះបណ្តាលប្រកបដោយភាពច្នៃប្រឌិត (ITMD) ដែលផ្តោតលើសកម្មភាពរកចំណូល។ គ្រឹះស្ថានដែលបានចូលរួមសកម្មភាពរកចំណូលនឹងទទួលបានសមត្ថភាពក្នុងការប្រកួតប្រជែង ព្រមទាំងការផ្តល់សេវាបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងផលិតភាព ដែលសិស្ស សហគមន៍ និងឧស្សាហកម្មទទួលយកបាន។ ទន្ទឹមនឹងនេះ គម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតម្រូវបង្កើតឱ្យមាន "**គោលការណ៍ណែនាំស្តីពីការរកចំណូលរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**" សម្រាប់លើកទឹកចិត្តគ្រឹះស្ថាន អ.ប.វ សាធារណៈសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការរកចំណូល។

អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថាគោលការណ៍ណែនាំនេះនឹងជួយដល់ការអនុវត្តយុទ្ធសាស្ត្រការអភិវឌ្ឍលើការគ្រប់គ្រង និងការបណ្តុះបណ្តាលប្រកបដោយភាពច្នៃប្រឌិត (ITMD) ក៏ដូចជាការពង្រឹងគុណភាពនៃសេវាបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទទួលបានផលជាវិជ្ជមាន។

ថ្ងៃ ចន្ទ ១រោច ខែ អស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០១៩

អគ្គនាយក

ហ៊ីង_ស៊ីដេត

មាតិកា

ខ្លឹមសារសង្ខេប.....5

១. សេចក្តីផ្តើម.....8

២. ដំណើរការនៃការអនុវត្តយុទ្ធសាស្ត្រ ITMD.....10

២.១. ការជ្រើសរើសក្រុមហ៊ុនមួយផ្តល់សេវាវគ្គបណ្តុះបណ្តាល ITMD និងជ្រើសរើសគ្រឹះស្ថាន អ.ប.វ ដើម្បីអនុវត្តសកម្មភាពរកចំណូល.....10

២.២. បង្កើតគោលការណ៍ណែនាំស្តីពីការអនុវត្តសកម្មភាពរកចំណូល.....11

២.៣. ការកសាងសមត្ថភាពនៃគ្រឹះស្ថាន អ.ប.វ ដោយក្រុមហ៊ុនផ្តល់សេវាពិគ្រោះយោបល់.....11

២.៤. ត្រួតពិនិត្យតាមដាន និងវាយតម្លៃអំពីការអនុវត្តសកម្មភាពរកចំណូលរបស់គ្រឹះស្ថាន អ.ប.វ.....11

៣. ការណែនាំ និងនីតិវិធីសម្រាប់គ្រប់គ្រងចំណូលដែលប្រមូលបានដោយ គ្រឹះស្ថាន អ.ប.វ.....12

៣.១. ទិដ្ឋភាពទូទៅអំពីច្បាប់/គោលនយោបាយអំពីការរកចំណូលដែលមានស្រាប់នៅ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ.....12

៣.២. និយមន័យ និងឱកាសនានានៃសកម្មភាពរកចំណូល.....12

៣.៣. វិធីគ្រប់គ្រងចំណូលដែលប្រមូលបាន.....13

៣.៣.១. ផែនការសកម្មភាពរកចំណូល និងផែនការអាជីវកម្ម.....13

៣.៣.២. ប្រព័ន្ធ/រចនាសម្ព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ.....13

៣.៣.៣. កត់ត្រា និងធ្វើរបាយការណ៍អំពីចំណូលដែលប្រមូលបាន.....14

៣.៣.៤. ការប្រើប្រាស់ និងគ្រប់គ្រងចំណូលដែលប្រមូលបាន.....14

៤. ឧបសម្ព័ន្ធ.....15

៤.១. ឧបសម្ព័ន្ធទី១៖ ម៉ូឌុលបណ្តុះបណ្តាលទាំង១៨ សម្រាប់កសាងសមត្ថភាពរបស់គ្រឹះស្ថាន អ.ប.វ.....15

៤.២. ឧបសម្ព័ន្ធទី២ ៖ ឧបករណ៍វាយតម្លៃគ្រឹះស្ថាន អ.ប.វ ដើម្បីចូលរួមក្នុងកម្មវិធីការអភិវឌ្ឍលើការគ្រប់គ្រង និងការបណ្តុះ បណ្តាលប្រកបដោយភាពច្នៃប្រឌិត (ITMD).....18

៤.៣. ឧបសម្ព័ន្ធទី៣ ៖ ព័ត៌មានលម្អិតអំពីសិក្ខាកាមដែលនឹងចូលរួមវគ្គបណ្តុះបណ្តាល ITMD.....22

៤.៤. ឧបសម្ព័ន្ធទី៤ ៖ ឱកាសរកចំណូល និងលក្ខណៈនៃការជ្រើសរើសគ្រឹះស្ថាន អ.ប.វ.....23

ខ្លឹមសារសង្ខេប

គម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVETSDP) ជាគម្រោងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយសមត្ថភាព ជំនាញ និងគុណភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ក្នុងរយៈពេលខ្លី និងវែង។ ឥទ្ធិពលនៃគម្រោងនេះនឹងធ្វើឲ្យមានកំណើនការងារដល់ពលរដ្ឋ ដែលទទួលបានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ។ លទ្ធផលរយៈពេលវែងនៃគម្រោង គឺប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ក្នុងពេលបច្ចុប្បន្ន និងអនាគត។ គម្រោងនេះរួមចំណែកក្នុងការដោះស្រាយបញ្ហាគុណភាព និងសមធម៌ ដែលវិស័យនេះកំពុងជួបប្រទះ តាមរយៈ (១)លើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (២)បង្កើនការចូលរៀនអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយសមធម៌ (៣)បង្កើនការចូលរួមរបស់និយោជកក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និង(៤)ពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

នៅក្នុងសៀវភៅណែនាំអំពីការអនុវត្តគម្រោង(PAM) លទ្ធផលមួយក្នុងចំណោមលទ្ធផលរំពឹងទុកទី៤ នៃគម្រោងនេះ គឺជាការពង្រឹងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ចាប់ពីកម្រិត២នៃក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជាឡើងទៅ ដោយមានការអនុវត្តយុទ្ធសាស្ត្រការអភិវឌ្ឍលើការគ្រប់គ្រង និងការបណ្តុះបណ្តាលប្រកបដោយភាពច្នៃប្រឌិត (ITMD)។ គ្រឹះស្ថានដែលបានចូលរួមសកម្មភាពរកចំណូលនឹងទទួលបានសមត្ថភាពក្នុងការប្រកួតប្រជែង ព្រមទាំងការផ្តល់សេវាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងផលិតភាពដែលសិស្ស សហគមន៍ និងឧស្សាហកម្មទទួលយកបាន។ ធនធានដែលគ្រឹះស្ថាន អ.ប.វ មានដូចជា ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគ្រូបង្រៀនដែលមានបទពិសោធន៍ការងារ អាចក្លាយជាកម្លាំងចលករសម្រាប់ ប្រើឲ្យអស់លទ្ធភាពក្នុងការរកចំណូល ក៏ដូចជាលើកកម្ពស់គុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ សកម្មភាពរកចំណូលគឺជាដំណើរការរបស់ស្ថាប័នមួយក្នុងការកំណត់ និងប្រើប្រាស់សកម្មភាពស្វែងរកប្រាក់ចំណូលនៅតាមគ្រឹះស្ថាន អ.ប.វ ផ្អែកលើឯកទេសជំនាញ រោងជាង វគ្គបណ្តុះបណ្តាល និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀតសម្រាប់ទទួលបានភាពគ្រប់គ្រាន់និងទំនួលខុសត្រូវចំពោះភាគីពាក់ព័ន្ធ។ សកម្មភាពរកចំណូលរាប់បញ្ចូលការបង្កើតគុណតម្លៃ តាមរយៈបង្កើនធនធានគ្រឹះស្ថានសម្រាប់ស្វែងរកប្រាក់ចំណូលដែលជួយក្នុងការកាត់បន្ថយភាពរាំងស្ទះផ្នែកហិរញ្ញវត្ថុ និងថែមទាំងផ្តល់ឱកាសនានាក្នុងការធ្វើឲ្យប្រសើរឡើងនូវបទពិសោធន៍សិក្សារបស់សិស្ស។

ដើម្បីអនុវត្តសកម្មភាពរកចំណូលបាន គ្រឹះស្ថាន អ.ប.វ ត្រូវការចាំបាច់នូវគោលការណ៍ណែនាំ ស្តីពីការរកចំណូលដែលត្រូវអនុម័តដោយនាយកគម្រោង។ ម្យ៉ាងទៀតគ្រឹះស្ថានទាំងនោះនឹងត្រូវកសាងសមត្ថភាព តាមរយៈ

វគ្គបណ្តុះបណ្តាល ITMD ។ ក្រុមហ៊ុនដែលទទួលខុសត្រូវក្នុងការបណ្តុះបណ្តាល នឹងរៀបចំវគ្គបណ្តុះបណ្តាលដល់សិក្ខាកាមដែលមក ពីគ្រឹះស្ថាន អ.ប.វ ដែលជ្រើសរើសឱ្យកសាងសមត្ថភាព និងអនុវត្តសកម្មភាពរកចំណូល។ សមាសភាពនៃសិក្ខាកាមរួមមាននាយក/នាយិកា នាយករង/នាយិការង មន្ត្រីគ្រឹះស្ថានទទួលបន្ទុកខាងរដ្ឋបាល និងហិរញ្ញវត្ថុ និងគ្រូបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។ ក្រុមការងារ ITMD (TASK FORCE) ទទួលភារកិច្ចក្នុងការត្រួតពិនិត្យ តាមដានទៅលើការអនុវត្តយុទ្ធសាស្ត្រ ITMD ឬសកម្មភាពរកចំណូល។ ដូចបានចែងក្នុងតារាងសង្ខេបនៃផែនការគម្រោង៣០% នៃ គ្រឹះស្ថាន អ.ប.វ នឹងចូលរួមក្នុងការអនុវត្តសកម្មភាពរកចំណូល (ប្រហែលជា៧គ្រឹះស្ថាន)។ ក្រុមការងារ ITMD (TASK FORCE) មានភារកិច្ចចុះត្រួតពិនិត្យតាមដានសកម្មភាពរកចំណូលរបស់គ្រឹះស្ថាន អ.ប.វ នីមួយៗ យ៉ាងហោចណាស់ម្តងក្នុង១ត្រីមាស។ គ្រឹះស្ថាននីមួយៗ ត្រូវមានរបាយការណ៍ស្តីពីការរកចំណូល ប្រចាំត្រីមាស នីមួយៗ និងឯកសារពាក់ព័ន្ធផ្សេងទៀត ដើម្បីឲ្យក្រុមការងារ ITMD អាចបំពេញភារកិច្ចត្រួតពិនិត្យតាមដានបានដោយរលូន និងដោយប្រសិទ្ធភាព។

មុននឹងអនុវត្តសកម្មភាពរកចំណូល គ្រឹះស្ថាន អ.ប.វ ដែលចូលរួមត្រូវស្នើផែនការសកម្មភាពរកចំណូលរបស់ខ្លួនទៅអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈក្រុមការងារ ITMD (TASK FORCE)។ វារឹតតែប្រសើរប្រសិនបើគ្រឹះស្ថាន អ.ប.វ អាចធ្វើផែនការអាជីវកម្មខ្លួនសម្រាប់សកម្មភាពរកចំណូលនីមួយៗដែលសាមីអង្គភាពគ្រោងនឹងធ្វើ។ គ្រឹះស្ថាន អ.ប.វ នីមួយៗអាចបង្កើតផែនការអាជីវកម្មជាក់លាក់មួយផ្អែកលើសកម្មភាពរកចំណូលមួយឬច្រើនដែលអង្គភាពខ្លួនកំណត់យក។

គ្រឹះស្ថាន អ.ប.វ នីមួយៗមានប្រព័ន្ធ និងបែបបទនៃការគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុនានារបស់ខ្លួន។ ប្រព័ន្ធ/រចនាសម្ព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដែលមានស្រាប់នៃគ្រឹះស្ថានទាំងនោះ អាចប្រើសម្រាប់កត់ត្រាចំណូល និងចំណាយនានាពីសកម្មភាពរកចំណូលបាន។ ចំណូលនីមួយៗ ត្រូវបានកត់ត្រា និងរាយការណ៍ឲ្យបានត្រឹមត្រូវដោយសាមីអង្គភាពដែលអនុវត្តសកម្មភាពរកចំណូលនេះដើម្បីឲ្យមានតម្លាភាពគ្រប់ចំណូលទាំងអស់ ដែលរកបានតាមផែនការសកម្មភាពរកចំណូល ត្រូវកត់ត្រាឲ្យបានល្អនៅក្នុងប្រព័ន្ធគណនេយ្យនៃគ្រឹះស្ថាន អ.ប.វ នីមួយៗ។ គ្រឹះស្ថាន អ.ប.វ នីមួយៗត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសជូនក្រុមការងារ ITMD (TASK FORCE) ដែលមានភារកិច្ចចុះត្រួតពិនិត្យតាមដានសកម្មភាពរកចំណូលនៅរៀងរាល់ត្រីមាស។

ប្រកាសរួមរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ៧១៤សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រកាសរួមរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ៧១៥ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការផ្តល់រង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃ សាធារណៈ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមូលដ្ឋាន

សម្រាប់ឱ្យគោលការណ៍ណែនាំនេះកំណត់ថាចំណូលពីការអនុវត្តសកម្មភាពរកចំណូលពីកម្មវិធី ITMD ត្រូវដក ១០% សម្រាប់ថវិការដ្ឋ ១% សម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ៨៩% សម្រាប់អ្នកអនុវត្តការផ្តល់សេវា។ ដូច្នេះចំណូលចំនួន៨៩% នេះគឺសម្រាប់ អង្គភាពយកទៅចាត់ចែងសម្រាប់ខ្ទង់ដូចខាងក្រោម៖

- ៦៥% សម្រាប់លើកទឹកចិត្តមន្ត្រីនៃសាមីអង្គភាពដែលចូលរួមអនុវត្តសកម្មភាពរកចំណូល
- ២០% សម្រាប់វិនិយោគបន្តដូចជា ជួសជុល ថែទាំ សាងសង់ ទិញថ្មី ឬអភិវឌ្ឍសាមីអង្គភាព។
- ៥% សម្រាប់ចំណាយផ្សេងៗរបស់សាមីអង្គភាព។
- ១០% សម្រាប់លើកទឹកចិត្តដល់មន្ត្រីនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលពាក់ព័ន្ធការរៀបចំ ការជំរុញ និងការតាមដានវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ITMD។

ល.រ	បំណែងចែកចំណូល	អត្រា
១	សម្រាប់ថវិការដ្ឋ	១០%
២	សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	១%
៣	**សម្រាប់អ្នកអនុវត្តការផ្តល់សេវា**	**៨៩%**
	៣.១ សម្រាប់លើកទឹកចិត្តមន្ត្រីនៃសាមីអង្គភាពដែលចូលរួមអនុវត្តសកម្មភាពរកចំណូល	*៦៥%*
	៣.២ សម្រាប់វិនិយោគបន្តដូចជា ជួសជុល ថែទាំ សាងសង់ ទិញថ្មី ឬអភិវឌ្ឍសាមីអង្គភាព	*២០%*
	៣.៣ សម្រាប់ចំណាយផ្សេងៗរបស់សាមីអង្គភាព	*៥%*
	៣.៤ សម្រាប់លើកទឹកចិត្តដល់មន្ត្រី នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងការរៀបចំ ការជំរុញ តាមដាន និងវាយតម្លៃទៅលើការអនុវត្តយុទ្ធសាស្ត្រ ITMD	*១០%*

១. សេចក្តីផ្តើម

គម្រោងអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVETSDP) ជាគម្រោងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយសមត្ថភាព ជំនាញ និងគុណភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ក្នុងរយៈពេលខ្លី និងវែង។ ឥទ្ធិពលនៃគម្រោងនេះនឹងធ្វើឲ្យមានកំណើនការងារដល់ពលរដ្ឋដែលទទួលបានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ។ លទ្ធផលរយៈពេលវែងនៃគម្រោងគឺប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារក្នុងពេលបច្ចុប្បន្ន និងអនាគត។

គម្រោងនេះរួមចំណែកក្នុងការដោះស្រាយបញ្ហាគុណភាព និងសមធម៌ ដែលវិស័យនេះកំពុងជួបប្រទះតាមរយៈ (១)លើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (២)បង្កើនការចូលរៀនអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយសមធម៌ (៣)បង្កើនការចូលរួមរបស់និយោជកក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និង(៤)ពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

នៅក្នុងសៀវភៅណែនាំអំពីការអនុវត្តគម្រោង (PAM) លទ្ធផលមួយក្នុងចំណោមលទ្ធផលរំពឹងទុកទី៤នៃគម្រោងនេះ គឺជាការពង្រឹងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ចាប់ពីកម្រិត២នៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាឡើងទៅ ដោយមានការអនុវត្តយុទ្ធសាស្ត្រការអភិវឌ្ឍលើការគ្រប់គ្រង និងការបណ្តុះបណ្តាលប្រកបដោយភាពច្នៃប្រឌិត (ITMD)។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយមន្ត្រីជំនាញ ក្រោមការសម្របសម្រួលពីអ្នកពិគ្រោះការអន្តរជាតិ និងជាតិ ដើម្បីកសាងសមត្ថភាពនៃគ្រឹះស្ថាន អ.ប.វ សាធារណៈ ក្នុងការអនុវត្តសកម្មភាពរកចំណូល។ សកម្មភាពរកចំណូលនេះមិនត្រឹមតែបម្រើការរកថវិកាជូនសាមីអង្គភាពប៉ុណ្ណោះទេ ប៉ុន្តែវាជាដំណើរការនៃការពង្រឹងការបញ្ជ្រាប និងការធ្វើឲ្យមាននិរន្តភាពដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈផងដែរ។ គ្រឹះស្ថានដែលបានចូលរួមសកម្មភាពរកចំណូលនឹងទទួលបានសមត្ថភាពក្នុងការប្រកួតប្រជែង ព្រមទាំងការផ្តល់សេវាអប់រំបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងផលិតភាពដែលសិស្ស សហគមន៍ និងឧស្សាហកម្មទទួលយកបាន។ ធនធានដែលគ្រឹះស្ថាន អ.ប.វ មានដូចជា ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគ្រូបង្រៀនដែលមានបទពិសោធន៍ការងារអាចក្លាយជាកម្លាំងចលករសម្រាប់ប្រើឲ្យអស់លទ្ធភាពក្នុងការរកចំណូលក៏ដូចជាលើកកម្ពស់គុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ បទពិសោធន៍ក្នុងការធ្វើធុរកិច្ចរបស់គ្រឹះស្ថាន អ.ប.វ នៅមានកម្រិត មានដូចជា គំនិតសហគ្រិនភាព ជំនាញក្នុងការធ្វើអាជីវកម្ម ជំនាញក្នុងការចរចា ជំនាញទំនាក់ទំនងជាមួយអតិថិជន និងក្រុមហ៊ុនឯកជនជាដើម ដែលធ្វើឲ្យកិច្ចខំប្រឹងប្រែងក្នុងការរក

ចំណូលជួបប្រទះឧបសគ្គជាច្រើន ដូចជាការគ្រប់គ្រងចំណូលពីការផលិត និងលក់ទំនិញឬសេវាកម្ម ការគិតគូរទៅលើថ្លៃដើម ចំណាយនានានៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

ដើម្បីអាចអនុវត្តសកម្មភាពរកចំណូលបាន យុទ្ធសាស្ត្រ ITMD ផ្តល់ជាអនុសាសន៍ដើម្បីលើកកម្ពស់ការកសាងសមត្ថភាពខាងសហគ្រិនភាព និងការគ្រប់គ្រង ព្រមទាំងផែនការសម្រាប់ផ្តល់វគ្គបណ្តុះបណ្តាល។ គោលបំណងរួមសំខាន់ នៃវគ្គបណ្តុះបណ្តាល គឺកសាងសមត្ថភាពរបស់គ្រឹះស្ថាន អ.ប.វ ដើម្បីអាចផ្តួចផ្តើម និងគ្រប់គ្រងសកម្មភាពរកចំណូល របស់អង្គភាពខ្លួន។ គោលបំណងជាក់លាក់នៃវគ្គបណ្តុះបណ្តាលទាំងនេះ ឬលទ្ធផលរំពឹងទុកនៃវគ្គមានដូចតទៅ៖

- មានគំនិតនៅក្នុងគ្រឹះស្ថាន អ.ប.វ ដើម្បីជ្រើសរើសឱកាសរកចំណូល ដែលសមស្របទៅ នឹងសមត្ថភាពរបស់ពួកគេ តាមរយៈការវាយតម្លៃសក្តានុពលទីផ្សារ និងធ្វើផែនការយុទ្ធសាស្ត្រអាជីវកម្ម។
- បញ្ចូលគោលនយោបាយ និងបទដ្ឋានច្បាប់ទៅក្នុងការគ្រប់គ្រងសកម្មភាពរកចំណូល។
- រៀបចំផែនការអនុវត្តសកម្មភាពរកចំណូល តាមរយៈការគ្រប់គ្រងដំណើរការចាប់ផ្តើម និងការប្រមូលធនធាន និងការទទួលបានការអនុញ្ញាតឱ្យរកចំណូល។
- គ្រប់គ្រងបុគ្គលិក និងប្រាក់ចំណូល ដើម្បីឱ្យអង្គភាពរីកចម្រើនជាលំដាប់ និងមាននិរន្តភាព។
- បង្កើតគំនិតច្នៃប្រឌិត និងដំណោះស្រាយ ដើម្បីទទួលបាននូវគុណសម្បត្តិប្រកួតប្រជែង។
- ប្រើជំនាញដែលសមស្រប និងបង្កើតដំណើរការ ដើម្បីគ្រប់គ្រងសកម្មភាពរកចំណូលប្រកបដោយប្រសិទ្ធភាព ជំនាញសហគ្រិនភាព អាជីវកម្ម និងការគ្រប់គ្រង។
- ផ្តួចផ្តើមឲ្យមានការចូលរួមរបស់វិស័យឯកជននៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

សកម្មភាពរកចំណូលអាចនាំមកនូវប្រព័ន្ធគ្រប់គ្រងមានលក្ខណៈនវានុវត្តន៍ ព្រមទាំងសហគ្រិនភាពសម្រាប់បង្កើតបាននូវឱកាស និងសមត្ថភាពថ្មីៗនៃសកម្មភាពរកចំណូល។

២. ដំណើរការនៃការអនុវត្តយុទ្ធសាស្ត្រ ITMD

ដ្យាក្រាមខាងក្រោមគឺជាគំនូសបំព្រួញនៃដំណើរការនានានៃការអនុវត្តយុទ្ធសាស្ត្រ ITMD ឬសកម្មភាពរកចំណូល ។



២.១. ការជ្រើសរើសក្រុមហ៊ុនមួយផ្តល់សេវាវគ្គបណ្តុះបណ្តាល ITMD និងជ្រើសរើសគ្រឹះស្ថាន អ.ប.វ ដើម្បី អនុវត្តសកម្មភាពរកចំណូល

ដើម្បីកសាងសមត្ថភាពគ្រឹះស្ថាន អ.ប.វ ក្នុងការរកចំណូល គេត្រូវជ្រើសរើសក្រុមហ៊ុនមួយផ្តល់សេវាវគ្គបណ្តុះបណ្តាល ITMD តាមរយៈលទ្ធកម្មគម្រោង។ ក្រុមហ៊ុននោះត្រូវមានកេរ្តិ៍ឈ្មោះ និងបទពិសោធន៍ល្អខាងការកសាងសមត្ថភាពរបស់គ្រឹះស្ថាន អ.ប.វ នៅបណ្តាប្រទេសនៃតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសនៅប្រទេសកម្ពុជា។ ក្រុមហ៊ុនក៏ត្រូវមានជំនាញនៃការបណ្តុះបណ្តាលផ្អែកលើសមត្ថភាព។ ក្រុមហ៊ុននោះត្រូវមានកំណត់ត្រានៃបទពិសោធន៍ល្អ ដើម្បីអាចត្រូវបានគេពិចារណាក្នុងការជ្រើសរើសសម្រាប់ការងារនេះ។

ផ្អែកតាមផែនការយុទ្ធសាស្ត្រ ITMD ដែលបានបង្កើតឡើង គ្រឹះស្ថាន អ.ប.វ ចំនួន២២ ដែលត្រូវចូលរួមអនុវត្តយុទ្ធសាស្ត្រនេះ ឬអនុវត្តសកម្មភាពរកចំណូល ត្រូវជ្រើសរើសពីគ្រឹះស្ថាន អ.ប.វ នៅតាមបណ្តុំគ្រឹះស្ថានភូមិភាគទាំង៥។ ក្រុមការងារ ITMD (TASK FORCE) ចូលរួមវាយតម្លៃគ្រឹះស្ថាន អ.ប.វ សាធារណៈទាំងនោះ ដោយប្រើឧបករណ៍វាយតម្លៃមួយដែលបានបង្កើតឡើង និងអនុម័តដោយគណៈកម្មការបច្ចេកទេសគម្រោង។ *ព័ត៌មានលម្អិតអំពីឧបករណ៍វាយតម្លៃនេះ សូមអាននៅក្នុងឧបសម្ព័ន្ធទី២ខាងក្រោម។*

២.២. បង្កើតគោលការណ៍ណែនាំស្តីពីការអនុវត្តសកម្មភាពរកចំណូល

ក្រោយពីអនុវត្តសកម្មភាពរកចំណូល ប្រាក់ចំណូលដែលប្រមូលបានដោយគ្រឹះស្ថាន អ.ប.វ អាចនាំមកនូវភាពស្មុគស្មាញក្នុងការគ្រប់គ្រង ប្រសិនបើមិនមានគោលការណ៍ណែនាំច្បាស់លាស់នោះទេ។ គោលការណ៍នេះនឹងអាចជួយគ្រឹះស្ថាន អ.ប.វ អនុវត្តសកម្មភាពរកចំណូលទាំងស្ថានភាពហិរញ្ញវត្ថុ និងការគ្រប់គ្រងបុគ្គលិក។

ក្រោយពេលអនុវត្តសាកល្បងដោយទទួលបានជោគជ័យ លិខិតគតិយុត្តិអនុញ្ញាតឲ្យគ្រឹះស្ថាន អ.ប.វ អាចអនុវត្តសកម្មភាពរកចំណូល និងការបែងចែកចំណូលនឹងត្រូវបានរៀបចំឡើង ដើម្បីឲ្យគ្រឹះស្ថានអាចអនុវត្តបានជាផ្លូវការ។ *សូមអានព័ត៌មានលម្អិតអំពីសិក្ខាកាមនៅក្នុងឧបសម្ព័ន្ធទី៣ខាងក្រោម។*

២.៣. ការកសាងសមត្ថភាពនៃគ្រឹះស្ថាន អ.ប.វ ដោយក្រុមហ៊ុនផ្តល់សេវាពិគ្រោះយោបល់

គ្រឹះស្ថាន អ.ប.វ ត្រូវការកសាងសមត្ថភាពក្នុងការអនុវត្តសកម្មភាពរកចំណូល។ មន្ត្រីជំនាញ និងក្រុមហ៊ុនទទួលខុសត្រូវបណ្តុះបណ្តាល នឹងរៀបចំវគ្គបណ្តុះបណ្តាលដល់សិក្ខាកាម ដែលមកពីគ្រឹះស្ថាន អ.ប.វ ដែលជ្រើសរើសឱ្យកសាងសមត្ថភាព និងអនុវត្តសកម្មភាពរកចំណូល។ សមាសភាពនៃសិក្ខាកាមរួមមាននាយក /នាយិកា នាយករង/នាយិការង មន្ត្រីគ្រឹះស្ថានទទួលបន្ទុកខាងរដ្ឋបាល និងហិរញ្ញវត្ថុ និងគ្រូបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។

២.៤. ត្រួតពិនិត្យតាមដាន និងវាយតម្លៃអំពីការអនុវត្តសកម្មភាពរកចំណូលរបស់គ្រឹះស្ថាន អ.ប.វ

ក្រុមការងារ ITMD ទទួលភារកិច្ចក្នុងការត្រួតពិនិត្យតាមដានទៅលើការអនុវត្តយុទ្ធសាស្ត្រ ITMD ឬសកម្មភាពរកចំណូល។ ដូចបានចែងក្នុងតារាងសង្ខេបនៃផែនការគម្រោង៣០% នៃគ្រឹះស្ថាន អ.ប.វ នឹងចូលរួមក្នុងការអនុវត្តសកម្មភាពរកចំណូល (ប្រហែលជា៧គ្រឹះស្ថាន)។ ក្រុមការងារ ITMD មានភារកិច្ចចុះត្រួតពិនិត្យតាមដានសកម្មភាពរកចំណូលរបស់គ្រឹះស្ថាន អ.ប.វ នីមួយៗ យ៉ាងហោចណាស់ម្តងក្នុង១ត្រីមាស។ គ្រឹះស្ថាននីមួយៗ ត្រូវមានរបាយការណ៍ស្តីពីការរកចំណូលប្រចាំត្រីមាសនីមួយៗ និងឯកសារពាក់ព័ន្ធផ្សេងទៀត ដើម្បីឲ្យក្រុមការងារ ITMD អាចបំពេញភារកិច្ចត្រួតពិនិត្យតាមដានបានដោយរលូន និងដោយប្រសិទ្ធភាព។

៣. ការណែនាំ និងនីតិវិធីសម្រាប់គ្រប់គ្រងចំណូលដែលប្រមូលបានដោយគ្រឹះស្ថាន អ.ប.វ

៣.១. ទិដ្ឋភាពទូទៅអំពីច្បាប់/គោលនយោបាយអំពីការរកចំណូលដែលមានស្រាប់នៅ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

កន្លងមកមានប្រកាសសំខាន់ៗពីរខាងក្រោមដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់ទាក់ទងនឹងការពង្រឹងយន្តការប្រមូល និងគ្រប់គ្រងចំណូលរបស់គ្រឹះស្ថានសាធារណៈក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ឯកសារទាំងនោះមាន៖

- ប្រកាសរួម រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ៧១៤សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- ប្រកាសរួមរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ៧១៥សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការផ្តល់រង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសាធារណៈ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្រៅពីនេះ មានប្រកាសដោយឡែកមួយទៀតគឺប្រកាសលេខ ៥១០ ក.ប/ប្រ.ក.ហ.ទ.រ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រង ចំណូលកម្រៃសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

យោងតាមខ្លឹមសារនៃប្រកាសទាំង៣ខាងលើ ចំណូលដែលបានមកពីការអនុវត្តសកម្មភាពរកចំណូលនានាតាមយុទ្ធសាស្ត្រ ITMD ដូចក្នុងតារាងទី៣ ខាងក្រោមនេះ នឹងមានមូលដ្ឋានច្បាប់អាចអនុវត្តបានទៅតាមគោលការណ៍ណែនាំនេះដែលនឹងអនុម័ត ដើម្បីសាកល្បងក្នុងអំឡុងពេលនៃគម្រោង។ ក្រោយពីការអនុវត្តតាមគោលការណ៍ណែនាំនេះ ព័ត៌មានត្រឡប់ និងមតិយោបល់ជាច្រើននឹងត្រូវប្រមូល ដើម្បីជាធាតុចូលសំខាន់សម្រាប់បញ្ចូលទៅក្នុងខ្លឹមសារនៃប្រកាសរួមរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣.២. និយមន័យ និងឱកាសនានានៃសកម្មភាពរកចំណូល

- និយមន័យ

សកម្មភាពរកចំណូល គឺជាដំណើរការរបស់ស្ថាប័នមួយក្នុងការកំណត់ និងប្រើប្រាស់សកម្មភាពស្វែងរកប្រាក់ចំណូលនៅតាមគ្រឹះស្ថាន អ.ប.វ ផ្អែកលើឯកទេសជំនាញ រោងជាង វគ្គបណ្តុះបណ្តាល និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀតសម្រាប់ទទួលបានភាពគ្រប់គ្រាន់ និងទំនួលខុសត្រូវចំពោះភាគីពាក់ព័ន្ធ។ សកម្មភាពរកចំណូលរាប់បញ្ចូលការបង្កើតគុណតម្លៃតាមរយៈបង្កើនធនធានគ្រឹះស្ថាន សម្រាប់ស្វែងរកប្រាក់ចំណូលដែលជួយក្នុងការកាត់

បន្ថយភាពរាំងស្ទះផ្នែកហិរញ្ញវត្ថុ និងថែមទាំងផ្តល់ឱកាសនានាក្នុងការធ្វើឲ្យប្រសើរឡើងនូវបទពិសោធន៍សិក្សារបស់សិស្ស។

ឱកាសនានានៃសកម្មភាពរកចំណូលដែលបានរកឃើញ

តាមរយៈសិក្ខាសាលាពិគ្រោះយោបល់អំពីយុទ្ធសាស្ត្រ ITMD សកម្មភាពរកចំណូលមួយចំនួនដែលមានសក្តានុពលរួមមាន ការបណ្តុះបណ្តាលកម្មករសម្រាប់និយោជក វគ្គសិក្សាខ្លីអំពីកុំព្យូទ័រ ថ្លៃបង់ចំណតយានជំនិះ ថ្លៃជួលសាលប្រជុំ ថ្លៃជួលអាហារដ្ឋាន (កង់ទីន) ថ្លៃសោហ៊ុយទស្សនារបស់សិស្សបរទេស ការតាំងបង្ហាញបច្ចេកវិទ្យាដល់សិស្ស មជ្ឈមណ្ឌលសេវាកម្មយានយន្ត មជ្ឈមណ្ឌលសេវាកម្មអគ្គិសនី ការងារតបណ្តាញទឹក កិច្ចសន្យាសាងសង់អគារ មជ្ឈមណ្ឌលផ្តល់សេវារៀបចំដី និងច្រូតកាត់ កិច្ចសន្យាផលិត (យកថ្លៃសេវាផលិត) ផ្សព្វផ្សាយលក់គ្រឿងបន្លាស់គ្រប់ប្រភេទ ជួសជុលអេឡិចត្រូនិក និងសេវាជ្រើសរើសបុគ្គលិក។

សូមអានព័ត៌មានលម្អិតអំពីឱកាសរកចំណូល និងលក្ខណៈនៃការជ្រើសរើសគ្រឹះស្ថាន អ.ប.វ នៅក្នុងឧបសម្ព័ន្ធទី៤ខាងក្រោម។

៣.៣. វិធីគ្រប់គ្រងចំណូលដែលប្រមូលបាន

៣.៣.១. ផែនការសកម្មភាពរកចំណូល និងផែនការអាជីវកម្ម

មុននឹងអនុវត្តសកម្មភាពរកចំណូល គ្រឹះស្ថាន អ.ប.វ ដែលចូលរួមត្រូវស្នើផែនការសកម្មភាពរកចំណូលរបស់ខ្លួនទៅអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈក្រុមការងារ ITMD (TASK FORCE)។ វារឹតតែប្រសើរ ប្រសិនបើគ្រឹះស្ថាន អ.ប.វ អាចធ្វើផែនការអាជីវកម្មរបស់ខ្លួនសម្រាប់សកម្មភាពរកចំណូលនីមួយៗ ដែលសាមីអង្គភាពគ្រោងនឹងធ្វើ។ គ្រឹះស្ថាន អ.ប.វ នីមួយៗអាចបង្កើតផែនការអាជីវកម្មជាក់-លាក់មួយ ផ្អែកលើសកម្មភាពរកចំណូលមួយ ឬច្រើនដែលអង្គភាពខ្លួនកំណត់យក។

៣.៣.២. ប្រព័ន្ធ/រចនាសម្ព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ

គ្រឹះស្ថាន អ.ប.វ នីមួយៗមានប្រព័ន្ធ និងបែបបទនៃការគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុនានារបស់ខ្លួន។ ប្រព័ន្ធ/រចនាសម្ព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដែលមានស្រាប់នៃគ្រឹះស្ថានទាំងនោះ អាចប្រើសម្រាប់កត់ត្រាចំណូល និងចំណាយនានាពីសកម្មភាពរកចំណូលបាន។

ចំណូលនីមួយៗត្រូវបានកត់ត្រានិងរាយការណ៍ ឲ្យបានត្រឹមត្រូវដោយសាមីអង្គភាពដែលអនុវត្តសកម្មភាពរកចំណូលនេះ។

៣.៣.៣. កត់ត្រា និងធ្វើរបាយការណ៍អំពីចំណូលដែលប្រមូលបាន

ដើម្បីឱ្យមានតម្លាភាព គ្រប់ចំណូលទាំងអស់ដែលរកបានតាមផែនការសកម្មភាពរកចំណូល ត្រូវកត់ត្រាឱ្យបានល្អនៅក្នុងប្រព័ន្ធគណនេយ្យនៃគ្រឹះស្ថាន អ.ប.វ នីមួយៗ។ គ្រឹះស្ថាន អ.ប.វ នីមួយៗ ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសជូនក្រុមការងារ ITMD (TASK FORCE) ដែលមានភារកិច្ចចុះត្រួតពិនិត្យតាមដានសកម្មភាពរកចំណូលនៅរៀងរាល់ត្រីមាស។

៣.៣.៤. ការប្រើប្រាស់ និងគ្រប់គ្រងចំណូលដែលប្រមូលបាន

ផ្អែកតាមខ្លឹមសារនៃប្រកាសសំខាន់ៗទាំងបីទាក់ទងនឹងការពង្រឹងយន្តការប្រមូល និងគ្រប់គ្រងចំណូលរបស់គ្រឹះស្ថានសាធារណៈក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចបានរៀបរាប់នៅក្នុងចំណុច៣.១ គោលការណ៍ណែនាំនេះកំណត់ថាចំណូលពីការអនុវត្តសកម្មភាពរកចំណូលពីកម្មវិធី ITMD ត្រូវដក ១០% សម្រាប់ថវិការដ្ឋ ១% សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង៨៩% សម្រាប់អ្នកអនុវត្តការផ្តល់សេវា។ ដូច្នេះចំណូលចំនួន ៨៩% នេះគឺសម្រាប់អង្គភាពយកទៅចាត់ចែងសម្រាប់ខ្ទង់ដូចខាងក្រោម៖

- ៦៥% សម្រាប់លើកទឹកចិត្តមន្ត្រីនៃសាមីអង្គភាពដែលចូលរួមអនុវត្តសកម្មភាពរកចំណូល
- ២០% សម្រាប់វិនិយោគបន្តដូចជា ជួសជុល ថែទាំ សាងសង់ ទិញថ្មី ឬអភិវឌ្ឍសាមីអង្គភាព។
- ៥% សម្រាប់ចំណាយផ្សេងៗរបស់សាមីអង្គភាព
- ១០% សម្រាប់លើកទឹកចិត្តដល់មន្ត្រី នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងការរៀបចំ ការជំរុញ តាមដាន និងវាយតម្លៃទៅលើការអនុវត្តយុទ្ធសាស្ត្រ ITMD។

ល.រ	បំណែងចែកចំណូល	អត្រា
១	សម្រាប់ថវិការដ្ឋ	១០%
២	សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	១%
៣	**សម្រាប់អ្នកអនុវត្តការផ្តល់សេវា**	៨៩%
	៣.១ សម្រាប់លើកទឹកចិត្តមន្ត្រីនៃសាមីអង្គភាពដែលចូលរួមអនុវត្តសកម្មភាពរកចំណូល	*៦៥%*
	៣.២ សម្រាប់វិនិយោគបន្តដូចជា ជួសជុល ថែទាំ សាងសង់ ទិញថ្មី ឬអភិវឌ្ឍសាមីអង្គភាព	*២០%*
	៣.៣ សម្រាប់ចំណាយផ្សេងៗរបស់សាមីអង្គភាព	*៥%*
	៣.៤ សម្រាប់លើកទឹកចិត្តដល់មន្ត្រី នៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងការរៀបចំ ការជំរុញ តាមដាន និងវាយតម្លៃទៅលើការអនុវត្តយុទ្ធសាស្ត្រ ITMD	*១០%*

៤. ឧបសម្ព័ន្ធ

៤.១. ឧបសម្ព័ន្ធទី១៖ ម៉ូឌុលបណ្តុះបណ្តាលទាំង១៨ សម្រាប់កសាងសមត្ថភាពរបស់គ្រឹះស្ថាន អ.ប.វ

តារាងទី១៖ សមត្ថភាពដែលត្រូវការបណ្តុះបណ្តាលសម្រាប់សកម្មភាពរកចំណូល	
ចំណងជើងនៃសមត្ថភាព/ម៉ូឌុល	តម្រូវការចាំបាច់សំខាន់ៗ/ប្រធានបទនៃការបណ្តុះបណ្តាល
១. សហគ្រិនភាព និងគំនិតច្នៃប្រឌិត និងការបង្កើតថ្មីរបស់គ្រឹះស្ថាន	• បង្កើតឲ្យមានសហគ្រិនភាពនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ • ការវេចខ្ចប់ផលិតផល និងសេវាកម្មតាមបែបថ្មី ហើយបង្កើតឱកាសទីផ្សារថ្មី • រចនាឡើងវិញនូវផលិតផលនិងសេវាកម្មសម្រាប់ការប្រកួតប្រជែងនៅក្នុងទីផ្សារ • បង្កើតធនធានឬការប្រើធនធានឲ្យមានកម្រិត ដើម្បីទទួលបានផលខ្ពស់ • បណ្តុះគំនិតសហគ្រិនភាពទាំងឥរិយាបថនិងការប្រព្រឹត្តិ
២. ការបង្កើតឱកាស ការកំណត់រក និងការធ្វើផែនទី (សកម្មភាពរកចំណូល បែបភាពច្នៃប្រឌិត)	• ការធ្វើផែនទីឬចងក្រងឯកសារអំពីឱកាសនានា ដូចជាទីផ្សារ អតិថិជន ព្រមទាំងតារាងចំណាយនិងចំណូល • កំណត់រកឲ្យឃើញឬបង្កើតនូវសកម្មភាពរកចំណូលថ្មី និងមានតែមួយប្លែកគេ • ប្រភពនានានៃឱកាស • ឱកាសប្លែកៗសម្រាប់ជំនាញខុសៗគ្នា • ការជ្រើសរើសសកម្មភាពរកចំណូល
៣. ស្រាវជ្រាវទីផ្សារអំពីសកម្មភាពរកចំណូលដែលបានជ្រើសរើស	• គម្លាតរវាងតម្រូវការ និងការផ្គត់ផ្គង់ • ធ្វើឲ្យឱកាសរកចំណូលដែលបានជ្រើសរើសរួចអាចធ្វើបាននិងទទួលបានជោគជ័យ • បង្កើតអង្កេត និងការប្រមូលទិន្នន័យអំពីសកម្មភាពរកចំណូល • ព័ត៌មានអំពីអ្នកប្រកួតប្រជែង • ការសរសេររបាយការណ៍ស្រាវជ្រាវទីផ្សារ
៤.ផែនការអាជីវកម្មស្តីពីសកម្មភាពរកចំណូល	• ណែនាំឲ្យមានការសរសេរផែនការអាជីវកម្ម • ផែនការកសាងសមត្ថភាពសម្រាប់សកម្មភាពរកចំណូល • ការបង្កើតយុទ្ធសាស្រ្តសកម្មភាពរកចំណូល • ការធ្វើផែនការសកម្មភាពរកចំណូល ការគ្រោងចំណាយ និងប្រាក់ចំណូល
៥. ធ្វើផែនការចាប់ផ្តើម និងការអនុវត្តសកម្មភាពរកចំណូល	• កាលវិភាគនៃសកម្មភាពនិងបែងចែកការទទួលខុសត្រូវលើសកម្មភាព • ការកៀងគរធនធានសម្រាប់អនុវត្តសកម្មភាពរកចំណូល • ស្វែងរកប្រភពដើមទុនចាប់ផ្តើម និងដើមទុនបង្វិល • រៀបចំផែនការចាប់ផ្តើមសម្រាប់សកម្មភាពរកចំណូលនីមួយៗដែលបានជ្រើសរើស

៦. ច្បាប់ និងបទបញ្ញាដែល អនុវត្ត ចំពោះសកម្មភាពរកចំណូល	• ទទួលបានការអនុញ្ញាតតាមគោលការណ៍ច្បាប់ និងអាជ្ញាប័ណ្ណ • ចុះបញ្ជីសិទ្ធិធ្វើអាជីវកម្ម-យីហោ • ចុះបញ្ជីការពារកម្មសិទ្ធិបញ្ញា • ប្រកាន់ខ្ជាប់នូវកាតព្វកិច្ចផ្លូវច្បាប់ • ការគិតពន្ធ និងការបង់ពន្ធ
៧.គ្រប់គ្រងការអនុវត្តសកម្មភាពរកចំណូល	• បង្កើតជំហានអនុវត្តផ្ទៃក្នុងសម្រាប់សកម្មភាពរកចំណូលនីមួយៗ • អនុវត្តជំហានសាកល្បងសម្រាប់សកម្មភាពរកចំណូលនីមួយៗ • បង្កើតប្រព័ន្ធអេក្[1]សម្រាប់ប្រតិបត្តិការសកម្មភាពរកចំណូល • ធានាថាសកម្មភាពរកចំណូលកំពុងអនុវត្តតាមគោលនយោបាយ និងប្រព័ន្ធច្បាប់ • ការបែងចែកការងារ
៨. ការគ្រប់គ្រងប្រតិបត្តិការ	• រៀបចំវគ្គបណ្តុះបណ្តាលថ្មីសម្រាប់វិស័យនិងសហគមន៍ • សំណើសុំថវិកាទៅរដ្ឋាភិបាលនិងម្ចាស់ជំនួយសម្រាប់ការបណ្តុះបណ្តាលដល់ក្រុម គោលដៅក្រីក្រ • រៀបចំរោងជាងបច្ចេកទេសសម្រាប់ផលិតកម្មនិងសេវាកម្មជាក់លាក់ដើម្បីដំណើរការបណ្តុះបណ្តាលជាក់ស្តែងដល់សិស្ស
៩. ការគ្រប់គ្រងលើខ្សែសង្វាក់ នៃការផ្គត់ផ្គង់	• ការទិញ និងការចែកចាយ • ការគ្រប់គ្រងសន្និធិទំនិញ • កាត់បន្ថយចំណាយប្រតិបត្តិការទៅលើខ្សែសង្វាក់នៃការផ្គត់ផ្គង់និងការចែកចាយ • កសាងទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ • ការគ្រប់គ្រងការលក់មិនទាន់បង់ប្រាក់ (លក់ជឿ)
១០. ការគ្រប់គ្រងគុណភាព	• ការកំណត់ស្តង់ដាគុណភាព • ប្រព័ន្ធពិនិត្យទៅលើគុណភាពនៃប្រតិបត្តិការ • ការធ្វើឲ្យសមស្របនូវគុណភាព និងជំនាញរបស់សិស្ស និង គ្រូបង្រៀន • បង្កើតការយកចិត្តទុកដាក់លើគុណភាពជាប្រចាំ • ការចំណាយ និងការចំណេញនៃការគ្រប់គ្រងគុណភាព
១១. ជំនាញធ្វើអាជីវកម្ម	• គ្រប់គ្រងផលអាជីវកម្មទាន់ពេលវេលា និងចំណាយតិចបំផុត • ប៉ាន់ស្មានពេលវេលានិងចំណាយ • ចរចាជាមួយអ្នកផ្គត់ផ្គង់ និងអតិថិជន
១២. ការគ្រប់គ្រងបុគ្គលិក និងគ្រូបង្រៀន	• ផ្តល់ការទទួលខុសត្រូវដល់បុគ្គលិក និងគ្រូបង្រៀនដែលមានចំណេះដឹង និង ធ្វើសមស្របនឹងសកម្មភាពរកចំណូល • ដាក់ការងារឲ្យត្រូវជំនាញ • អភិវឌ្ឍជំនាញគ្រប់គ្រងបែបសហគ្រិនភាព និងបែបអាជីវកម្ម • លើកទឹកចិត្តដល់បុគ្គលិក និងគ្រូ

[1] ប្រព័ន្ធអេក្រូសម្រាប់ផលិតកម្មនៃផលិតផលនិងសេវា

១៣. ការគ្រប់គ្រងចំណូល និងការពង្រីកការវិនិយោគ	• រៀបចំផែនការ និងយុទ្ធសាស្ត្រសម្រាប់ពង្រីកការវិនិយោគ • ការចែកប្រាក់ចំណូលដល់បុគ្គលិក និងគ្រូបង្រៀននៅគ្រឹះស្ថាន អ.ប.វ • ការគណនាប្រាក់ចំណូល និងការប្រមើលមើលពីហានិភ័យ • ការគ្រោងចំណូលរកបានទៅចំណាយក្នុងថវិកាប្រចាំឆ្នាំ • ការធ្វើបញ្ជីស្នាមប្រកបដោយតម្លាភាព • ការប្រកាសពីចំណូលដល់អ្នកពាក់ព័ន្ធ
១៤. ជំនាញកសាងក្រុមការងារ	• ការគ្រប់គ្រងជម្លោះ • បង្កើតក្រុមការងារដោយមានជំនាញបំពេញគ្នា • បង្កើតបរិយាកាសល្អសម្រាប់ការធ្វើការងារជាក្រុម • ការពង្រឹងក្រុមការងារ • ការបណ្តុះបណ្តាលក្រុមការងារ
១៥. ទំនាក់ទំនងអតិថិជន	• រៀបចំប្រព័ន្ធអេកូសម្រាប់កសាងបណ្តាញអតិថិជន • ការលើកកម្ពស់ការយល់ដឹងពីតំរូវការ និងបញ្ហារបស់អតិថិជន • ដោះស្រាយការតវ៉ារបស់អតិថិជន • ការយល់ឃើញរបស់អតិថិជន • បង្កើតកម្មវិធីលើកទឹកចិត្តរបស់អតិថិជន
១៦. យុទ្ធសាស្ត្រទីផ្សារ	• យុទ្ធសាស្ត្រផ្សព្វផ្សាយ • យុទ្ធសាស្ត្រកំណត់ថ្លៃលក់ចេញផលិតផល/សេវា • យុទ្ធសាស្ត្រចែកចាយ ផលិតផល/សេវាទៅតាមចំណែកទីផ្សារ • យុទ្ធសាស្ត្រផលិតផល/សេវា
១៧. ការគ្រប់គ្រងហិរញ្ញវត្ថុ	• ការធ្វើបញ្ជីស្នាម (កំណត់ត្រាចំណូលចំណាយ) • របាយការណ៍ហិរញ្ញវត្ថុ • អត្រាចំណេញពីអាជីវកម្ម • ការគ្រប់គ្រងលំហូរសាច់ប្រាក់ • ការគ្រប់គ្រងថ្លៃដើម
១៨. ការចូលរួមរបស់ វិស័យឯកជន	• រៀបចំកិច្ចប្រជុំ និងសហការជាមួយដៃគូនៃវិស័យ • ចរចាកិច្ចសន្យាភាពជាដៃគូ • ដឹកនាំទៅរកការចូលរួមរបស់វិស័យឯកជន • ការផ្តល់គុណតម្លៃដល់អ្នកពាក់ព័ន្ធ

៤.២. ឧបសម្ព័ន្ធទី២ ៖ឧបករណ៍វាយតម្លៃគ្រឹះស្ថាន អ.ប.វ ដើម្បីចូលរួមក្នុងកម្មវិធីការអភិវឌ្ឍលើការគ្រប់គ្រង និងការបណ្តុះបណ្តាលប្រកបដោយភាពច្នៃប្រឌិត (ITMD)

១. គោលបំណង និងវិធីសាស្ត្រ

ការជ្រើសរើសគ្រឹះស្ថាន អ.ប.វ មួយចំនួនដើម្បីចូលរួមសកម្មភាពកចំណូលគឺដើម្បីធានាថាគ្រឹះស្ថានទាំងនោះមានសក្តានុពលពិតប្រាកដ និងមានផែនការរបស់ខ្លួនច្បាស់លាស់សម្រាប់សកម្មភាពនេះ។ ម្យ៉ាងវិញទៀត ថវិកាសម្រាប់ការកសាង សមត្ថភាពដល់ គ្រឹះស្ថាន អ.ប.វ មានកំណត់ មានតែប្រមាណ៥០ភាគរយនៃគ្រឹះស្ថាន អ.ប.វ ទាំងអស់ ដែលស្ថិតនៅក្នុងបណ្តុំគ្រឹះស្ថាននៅភូមិភាគទាំង៥ នឹងត្រូវជ្រើសរើសសម្រាប់ការកសាងសមត្ថភាពនេះ។

ដូចនេះយើងត្រូវការជាចាំបាច់នូវឧបករណ៍វង្វាយតម្លៃគ្រឹះស្ថាន អ.ប.វ ដើម្បីជ្រើសរើសឲ្យចូលរួមក្នុងការកសាងសមត្ថភាពកចំណូល។ ក្រុមការងារ ITMD សហការនិងចូលរួមជាមួយជំនាញការជាតិដើម្បីបង្កើតឧបករណ៍នេះ ព្រមទាំងដាក់ ជូនក្រុមបច្ចេកទេសគម្រោងដើម្បីពិនិត្យ ផ្តល់យោបល់និងអនុម័ត។ បន្ទាប់មក ក្រុមការងារ ITMD នឹងចុះវាយតម្លៃនៅគ្រឹះស្ថាន អ.ប.វ ទាំងអស់ ដែលស្ថិតនៅក្នុងបណ្តុំគ្រឹះស្ថាននៅភូមិភាគទាំង៥ ព្រមទាំងដាក់ពិន្ទុនិងធ្វើចំណាត់ថ្នាក់។ គ្រឹះស្ថានទាំងអស់ នឹងត្រូវជូនដំណឹងអំពីលទ្ធផលនៃការជ្រើសរើស បន្ទាប់ពីការជ្រើសរើសត្រូវបានបញ្ចប់។

២. ឧបករណ៍វាយតម្លៃ

ក្រុមការងារ ITMD បានប្រជុំពិភាក្សាជាច្រើនលើកអំពីឧបករណ៍វង្វាយតម្លៃគ្រឹះស្ថាន អ.ប.វ ដែលនឹងត្រូវប្រើដើម្បីជ្រើសរើសឲ្យចូលរួមក្នុងការកសាងសមត្ថភាពកចំណូល ហើយបានដាក់ជូនអង្គប្រជុំក្រុមបច្ចេកទេសគម្រោងផ្តល់យោបល់កែសម្រួល និងអនុម័ត។ ជាលទ្ធផលចុងក្រោយគឺឧបករណ៍នេះខាងក្រោមដែលមានសរសេរលម្អិតនៅក្នុង ចំណុចក/ និងខ/ ដូចខាងក្រោមនេះ៖

ក/ តារាងដាក់ពិន្ទុគ្រឹះស្ថានតាមចំណុចវង្វាយតម្លៃ

ល.រ	ចំណុចដែលត្រូវវាយតម្លៃ	ពិន្ទុ	សម្គាល់
១	គ្រឹះស្ថាន អ.ប.វ ដែលមាន ការផ្តើមភាពជាដៃគូជាមួយវិស័យឯកជននិងដៃគូអភិវឌ្ឍន៍ខ្លះៗហើយ	១០	ភស្តុតាងជាកិច្ចសន្យា ឬអនុស្សរណៈ (MoU) ឬឯកសារពាក់ព័ន្ធផ្សេងទៀត
២	សក្តានុពលហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារបរិក្ខ (យោងឯកសារវាយតម្លៃគ្រឹះស្ថាន អ.ប.វ ដោយនាយកដ្ឋានធានាគុណភាព)	១០	• បន្ទប់ទ្រឹស្តី (២ពិន្ទុ) • រោងជាង/បន្ទប់ ពិសោធន៍ (២ពិន្ទុ) • បណ្ណាល័យ (២ពិន្ទុ) • សម្ភារអនុវត្ត (២ពិន្ទុ) • បរិស្ថានគ្រឹះស្ថាន អ.ប.វ(២ពិន្ទុ)

៣	គ្រឹះស្ថាន អ.ប.វ ដែលមានបើកវគ្គ VC, C1, C2, C3 ដែលផ្ដោតទៅ លើវិស័យអាទិភាពណាមួយ (មេកានិក សំណង់ កម្មន្តសាល ការងារអគ្គិសនី និង Business/ICT)	១០	វិស័យអាទិភាព១បានពិន្ទុ១០
៤	គ្រឹះស្ថាន អ.ប.វ នៅខេត្តដែលមានជនជាតិដើមភាគតិច	១០	ខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង និងព្រះវិហារ
៥	គ្រឹះស្ថាន អ.ប.វ ដែលបើកវគ្គបណ្ដុះបណ្ដាល សម្រាប់ជនពិការ	១០	មានភស្តុតាងបញ្ជាក់
៦	គំនិតផ្ដួចផ្ដើមនិងការដឹកនាំឆ្ពោះទៅរកចំណូល	៥០	វាយតម្លៃដោយក្រុមការងារ ITMD ដោយប្រើបញ្ជីសំណួរភ្ជាប់មកជាមួយខាងក្រោម

<u>ខ/ បញ្ជីសំណួរវាយតម្លៃទៅលើគំនិតផ្ដួចផ្ដើមនិងដឹកនាំឆ្ពោះទៅរកការរកចំណូល (សរុប៥០ពិន្ទុ)</u>

- ឈ្មោះសាលា៖...
- កាលបរិច្ឆេទនៃការវាយតម្លៃ៖...
- រយៈពេល២ម៉ោង ចាប់ពីម៉ោង...............ដល់ម៉ោង.................
- ឈ្មោះ សមាជិកគណៈគ្រប់គ្រងសាលា...តួនាទី
    - នាយក/នាយិកា៖......................................
    - នាយករង/នាយិការង៖...................................
    - ....
    - ....

☞☞☞មុននឹងឲ្យគណៈគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ ឆ្លើយសំណួរខាងក្រោម ក្រុមការងារ ITMD នឹងបង្ហាញត្រួសៗអំពីទស្សនទាននៃ ITMD ជាពិសេសជុំវិញការរកចំណូលដល់អ្នកចូលរួម (តាមរយៈPowerpoint)។

១. តើឱកាសរកចំណូលអ្វីខ្លះដែលគ្រឹះស្ថាន អ.ប.វ របស់អ្នកគិតថាអាចមាននាពេលអនាគតដ៏ខ្លីខាងមុខ? (១០ពិន្ទុ)

(ចម្លើយផ្តោតទៅលើចំណូលមិនមែនជាការបង់ថ្លៃសិក្សារបស់សិស្ស ហើយទាក់ទងនឹងជំនាញវិជ្ជាជីវៈជាចំបងនិងធនធានដែលមានស្រាប់)

- ....
- ....
- ....
- ....

២. តើគ្រឹះស្ថាន អ.ប.វ របស់អ្នកមានយុទ្ធសាស្ត្រដូចម្តេចដើម្បីចាប់យកឱកាសទាំងនោះ? (១០ពិន្ទុ)

(ចម្លើយផ្តោតទៅលើការប្រើប្រាស់ធនធានដែលមានស្រាប់ ការទាក់ទាញវិស័យឯកជននិងដៃគូអភិវឌ្ឍន៍ដែលឆ្លើយតបនឹងឱកាសរកចំណូលខាងលើ)

- ....
- ....
- ....
- ....

៣. នៅពេលរកបានចំណូល តើអ្នកនឹងយកចំណូលទាំងនោះទៅប្រើប្រាស់ដូចម្តេចខ្លះ? (១០ពិន្ទុ)

(ចម្លើយផ្តោតទៅលើយន្តការចែករំលែកចំណូលដល់បុគ្គលិក ការយកទៅអភិវឌ្ឍអង្គភាពអ្នកឲ្យមាននិរន្តភាព)

- ....
- ....
- ....
- ....

៤. ដើម្បីរកចំណូលបាន តើគ្រឹះស្ថាន អ.ប.វ ចង់ឲ្យមានការកសាងសមត្ថភាពអ្វីខ្លះ? (១០ពិន្ទុ)

(ចម្លើយផ្តោតទៅលើសមត្ថភាពអ្វីខ្លះដែលត្រូវការសម្រាប់អ្នកគ្រប់គ្រង បុគ្គលិក និងគ្រូជំនាញ ជាពិសេស សហគ្រិនភាព)

- ....

- ....
- ....
- ....

៥.តើអ្នកមានយុទ្ធសាស្ត្រជំរុញ និងលើកទឹកចិត្តបុគ្គលិក និងគ្រូដូចម្តេចខ្លះដើម្បីឲ្យពួកគាត់សកម្មចូលរួមក្នុងសកម្មភាពរបស់អង្គភាពរួមទាំងការរកចំណូល? (១០ពិន្ទុ)

(ចម្លើយផ្តោតទៅលើភាពជាអ្នកដឹកនាំនិងគ្រប់គ្រងស្ថាប័ន)

- ....
- ....
- ....
- ....

យើងខ្ញុំសូមអរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាដែលបានចំណាយពេលវេលាដ៏មានតម្លៃសហការយ៉ាងកក់ក្តៅ ផ្តល់ព័ត៌មានប្រកបដោយអត្ថប្រយោជន៍ដល់ក្រុមការងារយើងខ្ញុំ ។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

.... ថ្ងៃទី ខែ ឆ្នាំ២០១៨

បានឃើញ និង ឯកភាព

នាយក/នាយិកា

តំណាងក្រុមការងារឆ្លើយសំណួរ

៤.៣. ឧបសម្ព័ន្ធទី៣ ៖ព័ត៌មានលម្អិតអំពីសិក្ខាកាមដែលនឹងចូលរួមវគ្គបណ្តុះបណ្តាល ITMD

ប្រភេទសិក្ខាកាម	ចំនួនសិក្ខាកាមក្នុង១ក្រុម			
	ការអភិវឌ្ឍ និងការគ្រប់គ្រង ប្រព័ន្ធវិញ្ញាបនបត្រ គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ (TIMSDC-1)	TIMSDC- 2	TIMSDC-3	TIMSDC-4
នាយក/នាយិកា	៥	៦	៦	៥
នាយក/នាយិការង	៥	៦	៦	៥
គ្រូដែលត្រូវចូលរួម សកម្មភាពរកចំណូល	៥	៦	៦	៥
បុគ្គលិករដ្ឋបាល/គណនេយ្យ	៥	៦	៦	៥
មន្ត្រីនៃនាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា (ពាក់ព័ន្ធការងារ គ្រប់គ្រង និង ជំរុញសកម្មភាព រកចំណូលរបស់គ្រឹះស្ថាន អ.ប.វ)	១	១	១	១
សមាជិកក្រុមការងារ ITMD	២	២	២	២
សរុប	២៣	២៧	២៧	២៣

៤.៤. ឧបសម្ព័ន្ធទី៤ ៖ឱកាសរកចំណូល និងលក្ខណៈនៃការជ្រើសរើសគ្រឹះស្ថាន អ.ប.វ

ក្របខណ្ឌនៃការជ្រើសរើសគ្រឹះស្ថាន អ.ប.វ សម្រាប់សកម្មភាពរកចំណូល	
ឱកាសសម្រាប់សកម្មភាពរកចំណូល	**លក្ខណៈវិនិច្ឆ័យ (ដែលត្រូវកំណត់)**
ការជួលហេដ្ឋារចនាសម្ព័ន្ធ៖ (១)សាលប្រជុំ (២)ទីធ្លាសម្រាប់ព្រឹត្តិការផ្សេងៗ (៣)ចំណតរថយន្ត និង (៤)អាហារដ្ឋាន	• គ្រឹះស្ថាន អ.ប.វ ទាំងអស់ • ការវាយតម្លៃដើម្បីវិសាលភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះគឺទំនេរហើយអាចធ្វើបាន
ការបណ្តុះបណ្តាលសម្រាប់ជនបាត់បង់ឱកាស (១)យុវជនគ្មានការងារធ្វើ (២)ស្ត្រី (៣)ជនពិការ ឬ(៤)មនុស្សដែលត្រូវបានបណ្តេញចេញ ដែលផ្តល់មូលនិធិដោយ រដ្ឋាភិបាល និងម្ចាស់ជំនួយជាតិ និងអន្តរជាតិ	• គ្រឹះស្ថាន អ.ប.វ ទាំងអស់ • សមាមាត្រគ្រូ និងសិស្ស • កម្រិតការចុះឈ្មោះចូលរៀនរបស់សិស្ស
វគ្គបណ្តុះបណ្តាលនិងសេវាដល់និយោជក ៖ (១)វាយតម្លៃតម្រូវការការបណ្តុះបណ្តាលរបស់និយោជិត (២)ការបង្កើតវគ្គបណ្តុះបណ្តាលខ្លីៗជាក់លាក់សម្រាប់បង្កើនជំនាញ និង(៣)ផ្តល់សេវាវាយ តម្លៃជំនាញនិយោជិតសម្រាប់ការជ្រើសរើសបុគ្គលិក និងពិនិត្យទៅលើស្នាដៃការងារ	ជ្រើសរើសគ្រឹះស្ថានផ្អែកលើការវាយតម្លៃ៖ • គ្រូបណ្តុះបណ្តាលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងជំនាញធ្វើពាណិជ្ជកម្មជាក់លាក់ ដែលមានបទពិសោធន៍ក្នុងជំនាញខាងពាណិជ្ជកម្ម • មានបទពិសោធន៍សហការជាមួយវិស័យឯកជន ក្រុមហ៊ុនពី៣ទៅ៤ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលរបស់ក្រុមហ៊ុននៅគ្រឹះស្ថាន • សមាមាត្រគ្រូ និងសិស្ស • កម្រិតការចុះឈ្មោះចូលរៀនរបស់សិស្ស • រោងជាងបំពាក់ដោយម៉ាស៊ីននិងឧបករណ៍ថ្មីៗ
ផ្តល់សេវាបច្ចេកទេសដល់សហគ្រាសខ្នាតតូច៖ ការផ្តល់ជូននូវ (១)ការបណ្តុះបណ្តាលការងារដល់កម្មករនិយោជិត។ (២)ការថែរក្សាគ្រឿងម៉ាស៊ីន (៣)កែលម្អផលិតភាព (៤) Kaizen	• គ្រឹះស្ថានទាំងអស់-វាយតម្លៃសមត្ថភាព • គ្រូបណ្តុះបណ្តាលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងជំនាញធ្វើពាណិជ្ជកម្មជាក់លាក់ ដែលមានបទពិសោធន៍ក្នុងជំនាញខាង ពាណិជ្ជកម្ម
ផ្តល់សេវាថែទាំនិងជួសជុលនៅតាមគ្រួសារនិងកន្លែងអាជីវកម្ម (រៀបចំកិច្ចសន្យា)-ម៉ាស៊ីនត្រជាក់ ទូរទឹកកក រថយន្ត អគ្គិសនី និងបណ្តាញទឹក	• គ្រឹះស្ថានទាំងអស់-វាយតម្លៃសមត្ថភាព • សមាមាត្រគ្រូ និងសិស្ស • កម្រិតការចុះឈ្មោះចូលរៀនរបស់សិស្ស
បណ្តុះបណ្តាលបច្ចេកទេសអនុវត្តទីផ្សារនៃផលិតផលដែលបានបង្កើតឡើងក្នុងអំឡុងពេលបណ្តុះបណ្តាលបច្ចេកទេស និងជាផ្នែកមួយនៃការអនុវត្ត ជាក់ស្តែង	គ្រឹះស្ថាន អ.ប.វ ទាំងអស់

ប្រតិបត្តិការមជ្ឈមណ្ឌលផលិត	ជ្រើសរើសដោយផ្អែកលើ ៖ • គ្រូបណ្តុះបណ្តាលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងជំនាញធ្វើពាណិជ្ជកម្មជាក់លាក់ដែលមានបទពិសោធន៍ក្នុងជំនាញខាងពាណិជ្ជកម្ម • គ្រូមានជំនាញក្នុងដំណើរការផលិតនៅក្នុងឧស្សាហកម្មដែលបានជ្រើសរើស • បទពិសោធន៍ខាងទីផ្សារ និងខ្សែសង្វាក់ផ្គត់ផ្គង់ធ្វើឲ្យការផលិតផលិតផលជាក់លាក់អាចធ្វើទៅបាន • មានបទពិសោធន៍សហការជាមួយវិស័យឯកជន ក្រុមហ៊ុនពី៣ទៅ៤ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលឱ្យក្រុមហ៊ុន • រោងជាងបំពាក់ដោយម៉ាស៊ីននិងឧបករណ៍ថ្មីៗ • សមាមាត្រគ្រូ និងសិស្ស • មានសមត្ថភាពពេញលេញក្នុងទទួលសិស្សចុះឈ្មោះចូលរៀន • ១០០% សិស្សមានការងារធ្វើ • សម្ភាររោងជាងមានទីធ្លាទូលាយគ្រប់គ្រាន់ឬរៀបចំកន្លែងស្តុកគ្រប់គ្រាន់នៃវត្ថុធាតុដើមនិងផលិតផលសម្រេច

****កំណត់សម្គាល់៖*** *គ្រឹះស្ថាន អ.ប.វ នីមួយៗដែលចូលរួមក្នុងការអនុវត្តរកចំណូល មានសក្តានុពលនៃការរកចំណូលផ្សេងៗគ្នា ផ្អែកទៅលើការកំណត់និងចាប់យកឱកាសរកចំណូលរបស់គ្រឹះស្ថាន អ.ប.វ នីមួយៗ។*